ក្រសួងអប់រំ យុវជន និង កីឡា

១២

# ព្រៃឈើយើង



អង្គការកម្មវិធីមូលដ្ឋាន

នាយកដ្ឋានអប់រំក្រៅប្រព័ន្ធ

២០០៣

## អារម្ភកថា

តាមគោលការណ៍របស់ក្រសួងអប់រំ យុវជន និង កីឡា និង អនុលោមទៅតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល ដែលបានយកចិត្តទុកដាក់កាត់បន្ថយភាពក្រីក្ររបស់ប្រជាជន និង ចូលរួមធ្វើអោយបានសំរេចនូវទិសដៅ "**អប់រំសំរាប់ទាំងអស់គ្នា**" នាយកដ្ឋានអប់រំក្រៅប្រព័ន្ធដោយមានការជួយឧបត្ថម្ភពីអង្គការ**យូណេស្កូ** បានរៀបចំនិពន្ធសៀវភៅអក្ខរកម្មចំនួន ២៤ ក្បាល សំរាប់បងប្អូនប្រជាជនយើងរៀនសូត្រក្នុងរយៈពេល ២០០ ម៉ោង ។

ការនិពន្ធសៀវភៅទាំងអស់នេះបានផ្អែកលើខ្លឹមសារធំៗ ៤ តាមលំនាំនៃក្បួនគំរា ATLP គឺ : **ជីវភាពគ្រួសារ សេដ្ឋកិច្ចនិងប្រាក់ចំណូល សុខភាព** និង **ពលរដ្ឋវិជ្ជា** ដែលយើងអោយឈ្មោះថា កម្មវិធីអក្ខរកម្មផ្សារភ្ជាប់ទៅនឹងជីវភាពប្រចាំថ្ងៃ ។

សៀវភៅអក្ខរកម្មនេះត្រូវបានសាកល្បងនាឆ្នាំ ១៩៩៨-៩៩ ។ ក្រោយអនុវត្តសាកល្បងគណៈកម្មការនិពន្ធបានអញ្ជើញមន្ត្រីទទួលបន្ទុកការងារអប់រំក្រៅប្រព័ន្ធពីខេត្តកណ្ដាល កំពង់ឆ្នាំង ស្វាយរៀង ពោធិសាត់ កំពង់ស្ពឺ កំពង់ធំ ព្រៃវែង តាកែវ កំពត សៀមរាប បាត់ដំបង និង អង្គការក្រៅរដ្ឋាភិបាលមាន ADRA – CWDA និង ខេមរា មកប្រជុំកែលំអរទាំងខ្លឹមសារ អក្ខរាវិរុទ្ធ និង រូបភាព ពីថ្ងៃ ២០ ខែ ធ្នូ ឆ្នាំ ១៩៩៩ ។

ក្នុងការដាក់អោយប្រើប្រាស់សៀវភៅជាថ្មីនេះ យើងជឿជាក់ថាពិតជានៅមានការខ្វះខាតខ្លះៗពុំខានឡើយ។ ដូច្នេះ អ្នកនិពន្ធយើងខ្ញុំសូមសំណូមពរដល់លោកគ្រូ អ្នកគ្រូ និង មតិមហាជនទាំងអស់សូមជួយកែលំអ ដើម្បីអោយប្រជាជនយើងមានសៀវភៅរៀនសូត្រល្អ ហើយក្លាយទៅជាធនធានមនុស្សដែលមានសមត្ថភាពដោះស្រាយបញ្ហា និង កែលំអជីវភាពរបស់គេ គ្រួសារគេ ក៏ដូចជាប្រទេសជាតិអោយមានការរីកចំរើន រុងរឿងជាបន្តបន្ទាប់ ។

**គណៈកម្មការនិពន្ធ**

## អំពីព្យញ្ជនៈ

ក្ក ខ្ខ គ្គ ឃ្ឃ ង្ង

ច្ច ឆ្ឆ ជ្ជ ឈ្ឈ ញ្ញ

ដ្ដ ឋ្ឋ ឌ្ឌ ឍ្ឍ ណ្ណ

ត្ត ថ្ថ ទ្ទ ធ្ធ ន្ន

ប្ប ផ្ផ ព្ព ភ្ភ ម្ម

យ្យ រ្រ ល្ល វ្វ ស្ស ហ្ហ

ឡ្ឡ អ្អ

## អំពីស្រៈ

-ា -ិ -ី -ឹ -ឺ -ុ -ូ -ួ

-ើ -ឿ -ៀ េ- ែ- ៃ-

-ោ -ៅ -ុំ -ំ -ាំ -ះ -ុះ

-េះ -ោះ

## អំពីព្យញ្ជនៈបន្ថែម

ង៉ ញ៉ ប៉ ម៉ យ៉ រ៉ វ៉

អ៊ ប៊ ហ៊ ស៊

## អំពីស្រះពេញតួ

អ អា ឥ ឦ ឧ ឩ ឪ ឫ

ឬ ឭ ឮ ឯ ឰ ឱ ឳ

## អំពីលេខ

០ ១ ២ ៣ ៤ ៥

៦ ៧ ៨ ៩ ១០

0 1 2 3 4 5

6 7 8 9 10

# ព្រៃឈើយើង

## ១- អត្ថប្រយោជន៍នៃព្រៃឈើ

### ១-១ ចូរសិក្សារូបភាព និងអានចំនងជើងនៅខាងលើ និង ឃ្លានៅខាងក្រោម



ព្រៃល្អ( ព្រៃបៃតង)



ភ្នំត្រងិលគ្មានជីជាតិ

| ផលអាក្រក់នៃការបំផ្លាញព្រៃឈើ | អត្ថប្រយោជន៍នៃព្រៃឈើ |
| --- | --- |
| -ការកាប់បំផ្លាញព្រៃឈើធ្វើអោយភ្នំត្រងិល ដីខ្សោះជីជាតិទឹកភ្លៀងមិនបានជ្រាបចូលក្នុងដី<br>-បើគ្មានព្រៃឈើទេ ភ្នំមើលទៅគួរអោយធុញថប់ មិនគាប់ចិត្ត ។<br>-គ្មានព្រៃឈើនាំអោយមានការបាក់ដី ។<br>-ភ្នំត្រងិលគ្មានប្រយោជន៍អ្វីចំពោះភូមិទេ ។<br>-គ្មានព្រៃឈើ អាកាសធាតុក្តៅ ។ | - ព្រៃឈើជាធនធានធម្មជាតិ ផ្តល់ ម្ហូបអាហារ សត្វ ឈើ និងអុស<br>- ព្រៃឈើជួយការពារកុំអោយមានទឹកជំនន់ ព្រោះឫសវាធ្វើអោយទឹកជ្រាបចូលក្នុងដី ។<br>- ព្រៃឈើជួយអោយមានភ្លៀងធ្លាក់ទៀងទាត់<br>- ព្រៃឈើជួយអោយមានធាតុអាកាសត្រជាក់ល្មម ។<br>- ស្លឹកឈើរលួយ គឺជាជីធម្មជាតិល្អណាស់ |

## ១-២ ព្រៃឈើមានប្រយោជន៍អ្វីខ្លះ?

-ចូរជ្រើសរើសពាក្យចំនួន ៣ ដែលពាក់ព័ន្ធនឹងប្រយោជន៍ព្រៃឈើក្នុងចំណោមពាក្យខាងក្រោមនេះ :

ទឹកជំនន់     រាំងស្ងួត     ភ្លៀងទៀងទាត់

ទឹកជ្រាបក្នុងដី     អាកាសធាតុត្រជាក់ល្មម

-ចូរសរសេរអោយបានពីរឃ្លានឹងពាក្យសំខាន់នីមួយៗដែលជ្រើសរើសបាន ។

<u>ឧទាហរណ៍ឃ្លា</u>

១ : ព្រៃឈើជួយអោយមានភ្លៀងទៀងទាត់

២ : ភ្លៀងធ្លាក់ទៀងទាត់ធ្វើអោយព្រៃឈើដុះល្អមានពណ៌បៃតង

..............................................................................................................

..............................................................................................................

..............................................................................................................

..............................................................................................................

..............................................................................................................

ចូរស្រង់ពាក្យពាក់ព័ន្ធនឹងគ្រោះថ្នាក់បណ្ដាលមកពីការបំផ្លាញព្រៃឈើ ចេញពីរង្វង់ខាងក្រោម រួចសរសេរតាមបន្ទាត់ខាងក្រោម :

ខ្សោះជីជាតិ អាកាសធាតុក្ដៅ

ខ្វះភ្លៀង រាំងស្ងួត មានអុស ខ្វះអុស បាក់ដី

អស់ពូជសត្វ ទឹកជំនន់ រាស្ត្រក្រីក្រ

សំបូរជ័រឈើ មានភ្លៀង

..............................................................................................................

..............................................................................................................

..............................................................................................................

..............................................................................................................

..............................................................................................................

..............................................................................................................

១-៣ ចូរពិនិត្យ និង ពិភាក្សា



អស់ព្រៃឈើនាំអោយមានទឹកជំនន់



អស់ព្រៃឈើនាំអោយរាំងស្ងួត

សំនួរ : - ធ្វើដូចម្តេចកុំអោយមានទឹកជំនន់ និង ការរាំងស្ងួត ?

ដើម្បីកុំអោយមានទឹកជំនន់ និង ការរាំងស្ងួតត្រូវ :

....................................................................................................

....................................................................................................

....................................................................................................

....................................................................................................

....................................................................................................

....................................................................................................

....................................................................................................

....................................................................................................

២- មូលហេតុ នៃការវិនាសព្រៃឈើ

-ចូរសិក្សាផ្ទាំងរូបភាពខាងក្រោមនេះ និង និយាយអំពីអ្វីដែលអ្នកបាន ឃើញ រួចសរសេរនៅពីក្រោមរូប :



.............................................................................



.............................................................................



.............................................................................



.............................................................................

*អត្ថបទជំនួយស្មារតី*

# រឿង ព្រៃបៃតង

*ខ្ញុំជាព្រៃបៃតង ។ អ្នកភូមិទាំងឡាយមានមោទនភាពដោយសារខ្ញុំ ។ ពួកគេសំលឹងមកខ្ញុំដោយរីករាយ ។ ពួកគេមករកចំណីសត្វ ឈើ ផ្លែឈើ និង ស្មៅ ឱសថពីខ្ញុំ ។ ពួកគេកាប់តែដើមឈើណាដែលគ្រប់វ័យត្រូវកាប់តែប៉ុណ្ណោះ ។ ពួកគេដាំកូនឈើថ្មីនៅកន្លែងដើមឈើចាស់ ដូចនេះខ្ញុំនៅតែមានពណ៌បៃតងជានិច្ចកាល ។ ពួកគេបានថែទាំខ្ញុំយ៉ាងល្អ ។ ពួកគេមិនបណ្តែតបណ្តោយអោយ គោ ក្របី មកស៊ីកូនឈើរបស់ខ្ញុំឡើយ ។ ទឹកជ្រោះហូរកាត់ខ្ញុំទៅស្រោចស្រប់ដីស្រែចំការរបស់កសិករ សត្វព្រៃរស់នៅយ៉ាងសុខសាន្តជាមួយខ្ញុំ ។ អ្នកភូមិចង់អោយខ្ញុំនៅតែមានពណ៌បៃតង និង រីកធំធាត់តទៅទៀត ដើម្បីអោយខ្ញុំបញ្ចេញខ្យល់ល្អសំរាប់អោយមនុស្ស និង សត្វដកដង្ហើម ។ នេះគឺជាការ ល្អប្រសើរ ទាំងសំរាប់អ្នកភូមិ និង ទាំងសំរាប់ខ្ញុំផ្ទាល់ដែរ ។*

-ចូរឆ្លើយនឹងសំនួរដូចខាងក្រោមនេះ :

១- រឿងនេះមានគំនិតសំខាន់អ្វីខ្លះ ?

២- ផ្នែកសំខាន់ៗបំផុតរបស់រឿងមានអ្វីខ្លះ ?

......................................................................................................................

......................................................................................................................

......................................................................................................................

......................................................................................................................

*អត្ថបទជំនួយស្មារតី*

# រឿង ភ្នំត្រមិលខ្សោះដីជាតិ

ឥឡូវនេះ ខ្ញុំជាភ្នំត្រមិលគ្មានដីជាតិ ។ ពីម្ភៃឆ្នាំមុន ខ្ញុំមានពណ៌បៃតងដោយសារ ដើមឈើត្រសុំត្រសាយ និង ខ្សៅស្រងាត់ ។ កាលនោះ មានមនុស្សមកកាប់ដើមឈើ ដោយគ្មានពិចារណា ហើយមិនខ្វីទាំងដាំដើមឈើឡើងវិញទេ ដូចនេះហើយ ដើមឈើរបស់ខ្ញុំកាន់តែហោចតិចទៅៗ ទឹកជ្រោះក៏រីងស្ងួតអស់។ សត្វតូចសត្វធំទាំងឡាយរត់ចេញពីខ្ញុំអស់ ។ គេភ្លេចគិតដល់សារៈសំខាន់របស់ខ្ញុំ ហើយរូបខ្ញុំក៏ក្លាយទៅជាអស់ន័យគ្មានប្រយោជន៍ ។ មិនតែប៉ុណ្ណោះ ខ្លួនខ្ញុំថែមទាំងធ្វើអោយអ្នកភូមិរងគ្រោះទៀតផង ប្រសិនបើមានភ្លៀងធ្លាក់យ៉ាងខ្លាំងមកលើខ្ញុំ ។ ដីភ្នំខ្ញុំអាចនឹងបាក់ធ្លាក់ចុះទៅក្នុងភូមិ ហើយសង្កត់អ្នកភូមិទៀតផង ។

-ចូរឆ្លើយនឹងសំនួរដូចខាងក្រោមនេះ :

ស្អីទៅដែលជាគំនិតសំខាន់ៗក្នុងរឿងនេះ? ចូរសរសេរមួយឬពីរប្រយោគ

តើរឿងនេះ មានផ្នែកសំខាន់ៗអ្វីខ្លះ ?

ក-..........................................................................................................

ខ-..........................................................................................................

គ-..........................................................................................................

# ជីវភាពជនជាតិនៅខេត្តរតនគិរី

ខ្ញុំជាជនជាតិនៅខេត្តរតនគិរី នៅភូមិជិតស្ទឹងសេសាន ។ ខ្ញុំរកស៊ីដងជ័រពីដើមឈើធំៗនៅជុំវិញភូមិខ្ញុំ ដើម្បីធ្វើចន្លុះលក់ ។ ក្នុងដើមឈើមួយដើមខ្ញុំធ្វើចន្លុះលក់បាន ២០០០ រៀលក្នុងមួយថ្ងៃដែលជាចំណូលបន្ថែមលើផលដំណាំប្រចាំឆ្នាំរបស់គ្រួសារខ្ញុំ ។ ខ្ញុំសប្បាយរីករាយណាស់ក្នុងការរស់នៅរបស់ខ្ញុំ ។

ប៉ុន្តែឥឡូវនេះ បន្ទាប់ពីមានមនុស្សមកកាប់ឈើធំៗនេះដាក់ឡានដឹកយកទៅអស់ ខ្ញុំក៏ធ្លាក់ខ្លួនក្រលំបាក មិនអាចចិញ្ចឹមគ្រួសារបានទៅទៀតទេ ព្រោះខ្ញុំបាត់អាជីព ។ ខ្ញុំព្រួយចិត្តណាស់សព្វថ្ងៃនេះ ខ្ញុំត្រូវទៅកន្លែងឆ្ងាយទៀតទើបមានជ័រ ។ អ្នកភូមិខ្វះចន្លុះ ចន្លុះក៏ឡើងថ្លៃ ។ សត្វស្លាបធំក៏អស់ទ្រនំ ។ ទឹកជំនន់ក៏ខ្លាំងហូរបាក់ដីភូមិ និង ច្រាំងស្ទឹង ។ ដូច្នេះសូមកុំអោយមានមនុស្សមកកាប់ឈើរបៀបនេះតទៅទៀត ។

សំនួរ :

- ការកាប់ដើមឈើធំៗប៉ះពាល់អ្នកភូមិយ៉ាងណា ?
- បើកាប់ដើមឈើហើយ តើត្រូវធ្វើអ្វីខ្លះ ?
- យើងត្រូវរួមកំលាំងគ្នាដូចម្តេច ដើម្បីកុំអោយមានការកាប់ដើមឈើ ?

## ៣-ការដាំដើមឈើ



ការបណ្ដុះកូនឈើ



ការផ្សាំកូនឈើ



របៀបដាំកូនឈើ

## ៤-សំណួរពិភាក្សា

តើយើងគួរនាំគ្នាថែរក្សា ការពារព្រៃឈើដែរឬទេ? ព្រោះអ្វី ?

..........................................................................................................

..........................................................................................................

..........................................................................................................

## ៥-សិក្សាអក្សរ

៥.១- បង្ហាញ និង អានពាក្យគន្លឹះ :

- ព្រៃឈើ
- កាប់បំផ្លាញ
- ស្មៅឱសថ
- ច្រើន
- ភ្លើងឆេះព្រៃ
- រាំងស្ងួត

៥.២- អាន និង សរសេរពាក្យប្រកប :

| ☐ាញ | បំផ្លាញ | សាញ | ទាញ |
|---|---|---|---|

..........................................................................................................

| េ-ីន | ច្រើន | កើន | ចំរើន |
|---|---|---|---|

..........................................................................................................

| | | | |
|---|---|---|---|
| □ាំង | ទាំង | ខ្លាំង | អាំង |
| □ួត | ហួត | ជួត | ត្រួត |
| េ–ីង | ឡើង | ជើង | យើង |

៥.៣- អាន និង សរសេរពាក្យផ្ញើជើង

| | | | |
|---|---|---|---|
| ព្រ | ព្រៃ | ព្រាំ | ព្រោះ |
| ស្ម | ស្មា | ស្មាច់ | ស្មៅ |
| ផ្ល | ផ្លោង | ផ្លោះ | ផ្លាន |

| | | | |
|---|---|---|---|
| ភ្ល | ភ្លាម | ភ្លោះ | ភ្លឺ |
| ស្វ | ស្វាប | ស្វែរ | ស្វាត់ |

៥.៤- អាន និង សរសេរស្រះពេញតួ ៖

| | | | |
|---|---|---|---|
| ឥ | ឥទ្ធិពល | ឥឡូវ | ឥសី |
| ឮ | ឮសាន | | |
| ឧ | ឧទាហរណ៍ | ឧទ្ធរណ៍ | ឧកញ៉ា |
| ឪ | ឪពុក | ឪឡឹក | ឪឡ |
| ឫ | ឫកពា | ឫស្សី | ឫសឈើ |

| ឬ | ឬទេ? ............ |
|---|---|
| ឮ | ឮក ............ |
| ឭ | ឭ ឭឬទេ ? ............ |
| ឯ | ឯណា ឯករាជ្យ ............ |
| ឰ | ឰដ៏វេហាស៏ ............ |
| ឱ | ឱកាស ............ |
| ឳ | ក្រឳឈូក ............ |

៥.៥- អាន និង សរសេរពាក្យគន្លឹះ

| ព្រៃឈើ | ព្រៃឈើ | ព្រៃឈើ ............ |
|---|---|---|

............

| | | |
|---|---|---|
| ស្មៅឱសថ | ស្មៅឱសថ | ស្មៅឱសថ.................... |

..............................................................

| | | |
|---|---|---|
| កាប់បំផ្លាញ | កាប់បំផ្លាញ | កាប់បំផ្លាញ.................... |

..............................................................

| | | |
|---|---|---|
| ភ្លើងឆេះព្រៃ | ភ្លើងព្រៃឆេះ | ភ្លើងព្រៃឆេះ.................... |

..............................................................

| | | |
|---|---|---|
| រាំងស្ងួត | រាំងស្ងួត | រាំងស្ងួត.................... |

៥.៦- លំហាត់ ..............................................................

ក- ចូរតែងឃ្លា និង ពាក្យខាងក្រោម :

ព្រៃឈើ ..............................................................

ផ្កាផ្លែ ..............................................................

ស្មៅឱសថ ..............................................................

សត្វព្រៃ ..............................................................

កាប់បំផ្លាញ ..........................................................................................

ស្អាត ..........................................................................................

ច្រើន ..........................................................................................

ភ្លើង ..........................................................................................

ខ- ចូរសរសេរពាក្យអោយត្រូវនឹងរូបភាព :



..........................................................................................



..........................................................................................







គ- យើងអានឃ្លាខ្លីៗ :

ក. ព្រៃឈើយើងមានសំរស់ល្អត្រកាល ។

ខ. ក្នុងព្រៃឈើយើងមានផ្កា មានស្មៅឱសថ និង មានសត្វព្រៃជាច្រើន ។

គ. យើងនាំគ្នាការពារកុំអោយភ្លើងឆេះព្រៃ ។

ឃ. យើងត្រូវការពារព្រៃឈើអោយបាន ។

ង. យើងខំដាំដើមឈើឡើងវិញ ។

ឃ-ចូរគូសព្រួញពីឃ្លាឆ្វេងភ្ជាប់ទៅឃ្លាស្តាំ ដើម្បីអោយមានន័យត្រឹមត្រូវ:

| | |
|---|---|
| ក. ការកាប់ព្រៃឈើ | ដាំដើមឈើឡើងវិញ |
| ខ. យើងត្រូវ | មាននៅក្នុងព្រៃឈើជាច្រើន |
| គ. ស្មៅឱសថ | សំបូរដោយភ្លើងឆេះព្រៃ |
| ឃ. រដូវក្តៅ | អាចបណ្តាលអោយមានទឹកជំនន់ និង គ្មានភ្លៀង |

# ៦- រៀនលេខ ចំនួនពី ១000 ដល់ ៩00

៦.១- ការស្គាល់ខ្ទង់លេខ និង អាន :

១000 - ២000 - ៣000 - ៤000 -

៥000 - ៦000 - ៧000 - ៨000 - ៩៩៩៩

## ៦.២- វិធីអានចំនួនក្នុងតារាង

* យើងអានចំនួនពីឆ្វេងទៅស្តាំ :

<u>ឧទាហរណ៍ទី ១</u> :

| ពាន់ | រយ | ដប់ | រាយ |
|---|---|---|---|
| ១ | ៤ | ៥ | ៦ |

១៤៥៦ អានថា មួយពាន់ បួនរយ ហាសិបប្រាំមួយ ។

<u>ឧទាហរណ៍ទី ២</u> :

| ពាន់ | រយ | ដប់ | រាយ |
|---|---|---|---|
| | ៥ | ២ | ៨ |
| ២ | ០ | ៥ | ០ |
| ៦ | ០ | ០ | ៣ |
| ១ | ២ | ០ | ០ |
| ៩ | ៩ | ៩ | ៩ |

៥២៨ អានថា ប្រាំរយម្ភៃប្រាំបី

២០៥០ អានថា ពីរពាន់ហាសិប

៦០០៥ អានថា ប្រាំមួយពាន់ប្រាំ

១២០០ អានថា មួយពាន់ពីររយ

៩៩៩៩ អានថា ប្រាំបួនពាន់ប្រាំបួនរយ កៅសិបប្រាំបួន

៦.៣-វិធីបញ្ចាក់លេខចែក

ក-របៀបរកតួចែក ផលចែក និង តំណាងចែក

<u>ឧទាហរណ៍</u> : ១២៥ ៖ ២៥ = ៥ ឬ

| | | | | |
|---|---|---|---|---|
| តំណាងចែក → | ១២៥ | ២៥ | ← | តួចែក |
| សំណល់ → | ០០ | ៥ | ← | ផលចែក |

**តំណាងចែក = តួចែក X ផលចែក**

ឬ ( តួចែក X ផលចែក ) + សំណល់

( ២៥ X ៥ ) + ០០

**តួចែក = តំណាងចែក ៖ ផលចែក**

១២៥ ៖ ៥ = ២៥

**ផលចែក = តំណាងចែក ៖ តួចែក**

១២៥ ៖ ២៥ = ៥

ខ- ចូរបំពេញវិធីចែកខាងក្រោម :

| | | | | | |
|---|---|---|---|---|---|
| ……… | ១ ៣ | ……… | ១ ៣ | ១១០៤ | ……… |
| ……… | ១ ៧ | ១ ១ | ១ ៧ | ……… | ១ ៧ |

គ- លំហាត់លើក្តារឆ្នួន

4798 ៖ 63 =……..    7040 ៖ 41 =……….

5989 ៖ 71 =……..    3353 ៖ 52 =……….

ឃ- លំហាត់សរសេរ

៥២១៧ + ៩៦៥ =…………….

៦០២០ + ៣៥៧៥ =…………….

៣១៨៩ + ២៧៥៣ =…………….

9023 - 6845 =...............

8527 - 7872 =...............

6135 - 967 =...............

2054 - 97 =...............

1806 + 68 =...............

150 X 20 =...............

215 X 40 =...............

58 X 90 =...............

79 X 42 =...............

2504 ÷ 42 =...............

9500 ÷ 32 =...............

8720 ÷ 50 =...............

ង- ចំណោទងាយៗ

១- ម្តាយមីងខ្ញុំដាំកូនឈើបាន ៣២ ជួរ ។ ក្នុងមួយជួរដាំបាន ១២០ ដើម។ ខ្ញុំដាំបាន ៥២០ ដើមទៀត ។ សួរថា តើម្តាយមីងខ្ញុំ និង ខ្ញុំដាំកូនឈើបានប៉ុន្មានដើម ? ។

<u>ចំលើយ</u>

ម្តាយមីងខ្ញុំដាំកូនឈើបាន

១២០ ដើម X ៣២ =............ ដើម

ចំនួនដើមឈើដែលខ្ញុំ និង ម្តាយមីងខ្ញុំដាំបាន

............ + ៥២០=.......... ដើម

ឆ្លើយថា : ម្តាយមីងខ្ញុំ និង ខ្ញុំដាំកូនឈើបាន ............ ដើម

២- យើងដាំដើមឈើបាន ៦១៥២ ដើម ។ កាប់មែកធ្វើអុសលក់បានក្នុងមួយខែ ៥០០០ រៀល ។ តើក្នុងមួយឆ្នាំបានប៉ុន្មានរៀល ? ។

ចំលើយ

លុយដែលបានមកពីការកាប់អុសក្នុងមួយឆ្នាំ

៥០០០ រៀល X ១២ ខែ =............ រៀល

ឆ្លើយថា : ក្នុងមួយឆ្នាំលក់បានចំនួន ................ រៀល

# អនុវត្តន៍

១- យកគ្រាប់ស្វាយ អំពិល ខ្នុរ ....មកបណ្ដុះម្នាក់អោយបានដប់គ្រាប់ :



២- ពិនិត្យ និង ពិភាក្សា



យើងដាក់ជីរនៅក្រោមជាយម្លប់ចុងមែក



៣- យើងកប់ក្អមមានទឹកពេញ មានគំរបក្រោមដាយម្លប់ចុងមែក

..........................................................................................................

..........................................................................................................

..........................................................................................................

៤- តើឧទ្យានជាតិក្នុងប្រទេសកម្ពុជាមានប៉ុន្មាន? ឈ្មោះអ្វីខ្លះ ?

..........................................................................................................

..........................................................................................................

៥- ដើមឈើសំរាប់ធ្វើសំណង់ ( ផ្ទះ សាលារៀន) មានឈ្មោះអ្វីខ្លះ?

..........................................................................................................

..........................................................................................................

៦- ចូររៀបរាប់ និង សរសេរឈ្មោះដើមឈើសំរាប់ធ្វើគ្រឿងតុបតែងលំអផ្សេងៗ

..........................................................................................................

..........................................................................................................

៧- នៅក្នុងដីភូមិអ្នក មានដាំដើមឈើធំៗឬទេ? អ្វីខ្លះ?

..........................................................................................................

..........................................................................................................

..........................................................................................................

៨- តើអ្នកចូលចិត្តបរិភោគផ្លែឈើឈ្មោះអ្វីខ្លះ? ចូររៀបរាប់ និង សរសេរ

..........................................................................................................

..........................................................................................................

..........................................................................................................

៩- ដើមឈើស៊ីផ្លែសំរាប់យកមកធ្វើជាម្ហូបឈ្មោះអ្វីខ្លះ?

..........................................................................................................

..........................................................................................................

..........................................................................................................

១០- ដើមឈើស៊ីផ្លែសំរាប់យកមកធ្វើជាបង្អែមឈ្មោះអ្វីខ្លះ?

.......................................................................................................................................

.......................................................................................................................................

.......................................................................................................................................

១១- ដើមឈើដែលយើងយកស្លឹក ផ្កា មកបរិភោគ ជាបន្លែឈ្មោះអ្វីខ្លះ?

.......................................................................................................................................

.......................................................................................................................................

.......................................................................................................................................

# ការប្រើប្រាស់ម៉ាស៊ីនគិតលេខ




- គ្រូត្រូវបង្រៀនសិស្សអោយចេះប្រើម៉ាស៊ីនគិតលេខ ។
- សិស្សត្រូវចេះ

    ១- បើកបិទម៉ាស៊ីន

    ២- ដាក់ម៉ាស៊ីនអោយនៅលេខសូន្យ

    ៣- ប្រើវិធីដក (-) បូក (+) គុណ (x) ចែក (៖)

    ៤- ប្រើសញ្ញាស្មើ (=) សំរាប់បញ្ចេញលទ្ធផល ។

## I-អ្នកនិពន្ធ

អ្នកស្រី ពីង សយ ធ្វើការនៅអង្គការ ARCC

## II-គណៈកម្មការរៀបរៀង

១- លោក សូ ឈុន សមាជិកក្រុមជំនួយការក្រសួងអប់រំ យុវជន និង កីឡា

២- លោក អ៊ិន ថេរ ប្រធាននាយកដ្ឋានអប់រំក្រៅប្រព័ន្ធ

៣- លោក ណុប ទីម ជំនួយប្រធាននាយកដ្ឋានអប់រំក្រៅប្រព័ន្ធ

៤- លោកស្រី ហេង ស៊ីផុន ប្រធាននាយកដ្ឋានអប់រំបណ្តុះបណ្តាល នៃក្រសួងកិច្ចការនារី

៥- លោក កេត សម្បត្តិ ប្រធានការិយាល័យអក្ខរកម្ម នៃនាយកដ្ឋានអប់រំក្រៅប្រព័ន្ធ

៦- អ្នកស្រី ធាំ ស៊ឿង អនុប្រធានការិយាល័យអភិវឌ្ឍន៍កម្មវិធី និង សៀវភៅសិក្សា នៃនាយកដ្ឋានអប់រំក្រៅប្រព័ន្ធ

## III-ទីប្រឹក្សា

លោក សុផ្គោច សែនស៊ុន (Dr. Suport Prasertsri) អ្នកឯកទេសវិស័យអប់រំ UNESCO ប្រចាំកម្ពុជា

## IV-អ្នកវាយកុំព្យូទ័រ

លោក ឈិន វុិត មន្ត្រីការិយាល័យអភិវឌ្ឍន៍កម្មវិធី និង សៀវភៅសិក្សា នៃនាយកដ្ឋានអប់រំក្រៅប្រព័ន្ធ

## V-អ្នកគូររូប

លោក ឯម សត្យា

## VI-អាស័យដ្ឋាននាយកដ្ឋានអប់រំក្រៅប្រព័ន្ធ

អគារលេខ ១៦៩ មហាវិថីព្រះនរោត្តម សង្កាត់បឹងកេងកង។ ខ័ណ្ឌចំការមន រាជធានីភ្នំពេញ។

**សូមថ្លែងអំណរគុណ**

ដល់អង្គការ យូណេស្កូ ដែលបានជួយឧបត្ថម្ភ

ទាំងសំភារៈ ថវិកា និង បច្ចេកទេស ក្នុងការនិពន្ធ និង រៀបរៀង

បានទទួលការអនុញ្ញាតអោយបោះពុម្ពផ្សាយពីក្រសួងអប់រំ យុវជន និង កីឡា
តាមសេចក្តីប្រកាសលេខ ៥៦៣ អយក.ប្រក ចុះថ្ងៃទី ១១ ខែ មិថុនា ឆ្នាំ ១៩៩៨
ដើម្បីប្រើប្រាស់នៅតាមថ្នាក់អក្ខរកម្ម (ថវិកាជាតិ ឆ្នាំ២០០៣) ។

"ហាមថតចំលង"